# ប្រវត្តិ រសស:

រដ្ឋាករទឹកសៀមរាប ត្រូវបានបង្កើតឡើងក្នុងអំឡុងឆ្នាំ១៩៣០ ដោយអាណានិគមបារាំង ដែលមានសមត្ថភាពផលិត ១០០ម៣/ថ្ងៃ ដោយយកប្រភពទឹកស្ទឹងសៀមរាប និងមានបំពង់ចែកចាយទឹកតែ២ខ្សែប៉ុណ្ណោះគឺ ផ្គត់ផ្គង់ទឹកទៅមហាសណ្ឋាគារអង្គរ និងតំបន់ផ្សារចាស់។ នៅឆ្នាំ១៩៦០ ក្រោមហិរញ្ញប្បទានឥតសំណងពីសហរដ្ឋអាមេរិច និងចិន សមត្ថភាពផលិតបានកើនឡើងដល់ ៥០០ម៣/ថ្ងៃ ហើយស្ថានភាពនេះបន្តរហូតមកដល់ឆ្នាំ១៩៧៥ ។ ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនេះ ត្រូវបានទុកចោលមិនដំណើរការ និងបំផ្លាញឱ្យវិនាសហិនហោចស្ទើរគ្មានសល់ ក្នុងរបបប្រល័យពូជសាសន៍ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។

ក្រោយថ្ងៃជ័យជំនះ ៧ មករា ឆ្នាំ១៩៧៩ រដ្ឋាករទឹកសៀមរាប បានចាប់ផ្តើមដំណើរការឡើងវិញជាមួយនឹងប្រព័ន្ធផលិតកម្ម និងចែកចាយទឹកដ៏ចាសទ្រុឌទ្រោម ។ ដោយសារស្ថានភាពកាន់តែដុនដាប ពុំអាចដំណើរការទៅទៀតបាន ប្រព័ន្ធផ្គត់ផ្គង់នេះ ត្រូវបានបញ្ឈប់ទាំងស្រុងនៅឆ្នាំ១៩៩៤ រហូតដល់ឆ្នាំ១៩៩៨ ។ ចាប់ពីឆ្នាំ១៩៩៥ ក្រោមជំនួយឧបត្ថម្ភពីរដ្ឋាភិបាលបារាំង តាមរយៈទីភ្នាក់ងារអភិវឌ្ឍបារាំង AFD បានជួយជួសជុលកែសម្រួលប្រព័ន្ធផលិតកម្មជាបន្តបន្ទាប់ ដោយប្តូរពីការយកប្រភពទឹកស្ទឹងសៀមរាប ទៅយកប្រភពទឹកក្រោមដី ហើយដាក់ឱ្យដំណើរការឡើងវិញនៅឆ្នាំ១៩៩៨ ដែលមានសមត្ថភាពផលិត ១ ៤០០ម៣/ថ្ងៃ និងមានបណ្តាញចែកចាយ១២គីឡូម៉ែត្រសុទ្ធសឹងជាបំពង់ស៊ីម៉ង់ប្រភេទAC ។

ដំណាក់កាលវិវឌ្ឍដ៏សំខាន់របស់រដ្ឋាករទឹកសៀមរាប គឺនៅឆ្នាំ២០០៦ ក្រោមគម្រោងហិរញ្ញប្បទានឥតសំណងពីរាជរដ្ឋាភិបាល និងប្រជាជនជប៉ុន តាមរយៈទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន(JICA) មានទឹកប្រាក់សរុប ១ ៥៣៧លានយ៉េន ស្មើនឹង១៥ ៣៧០ ០០០ដុល្លាអាមេរិច បានសាងសង់នូវប្រព័ន្ធប្រព្រឹត្តកម្មទឹកស្អាតថ្មីទាំងស្រុងមួយ ស្ថិតនៅសង្កាត់ទឹកវិល ក្រុងសៀមរាប ដែលមានសមត្ថភាពផលិត ៨ ០០០ម៉ែត្រគូប/ថ្ងៃ ដោយយកប្រភពទឹកក្រោមដីពីអណ្តូង ចំនួន០៨កន្លែង និងបណ្តាញចែកចាយទឹកប្រភេទ PVC ប្រវែង៣៦គីឡូម៉ែត្រ ធ្វើឱ្យរដ្ឋាករទឹកសៀមរាបមានលទ្ធភាពផ្គត់ផ្គង់ទឹក ជូនប្រជាពលរដ្ឋបានចំនួន ០៥សង្កាត់ (សង្កាត់ស្លក្រាម សង្កាត់ស្វាយដង្គំ សង្កាត់គោកចក សង្កាត់សាលាកំរើក និងសង្កាត់ទឹកវិល ។

ផ្តើមចេញពីនេះរដ្ឋាករទឹកស្វយ័តសៀមរាប(រ.ស.ស) ត្រូវបានបង្កើតឡើង ដោយអនុក្រឹត្យលេខ០៤ អនក្រ.បក ចុះថ្ងៃទី ១០ ខែមករា ឆ្នាំ២០០៧ ជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច ស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេស នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រោមអាណាព្យាបាលហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលដឹកនាំដោយក្រុមប្រឹក្សាភិបាលមានសមាជិកចំនួន០៧រូប និងអមដោយមន្ត្រីត្រួតពិនិត្យចំនួន០១រូប។